មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្ត កណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

====

## ២. សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០១

### សេចក្តីសំរេចលេខ ៣៣ សសរ
### ស្តីពីការធ្វើវិសោធនកម្មលើសេចក្តីសំរេចលេខ ០៧ សសរ
### ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគនៃ ព្រះរាជាណាចក្រកម្ពុជា

-យោងអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យកែតំរូវលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩

www.pheakdeylaw.com

-យោងអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩

-យោងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ០៧ សសរ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន

-យោងសេចក្តីជូនដំណឹងលេខ ១៩៩ សជណ.សរ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល វិស័យឯក ជនលើកទី៣ នាថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១** : បង្កើតក្រុមការងារផ្នែកសេវាកម្មធនាគារ និងហិរញ្ញវត្ថុ ជំនួសអោយក្រុមការងារផ្នែកសេវាកម្ម រាប់បញ្ចូលទាំងសេវាធនាគារ និងហិរញ្ញវត្ថុ ដែលមានចែងក្នុងសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១ ។

**ប្រការ ២** : ក្រុមការងារផ្នែកសេវាកម្មធនាគារ និងហិរញ្ញវត្ថុនេះ មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១-ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាល ធនាគារជាតិ នៃកម្ពុជា | ប្រធាន |
| ២-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្តម **សុន គន្ធរ** ប្រធានអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៤-ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦-ឯកឧត្តម**សុវណ្ណ សុធន្ន** អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិក |
| ៧-ឯកឧត្តម **សយ សុខា** អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |

**ប្រការ ៣** : បន្ថែមភារកិច្ចក្នុងចំណុច " ឃ " ប្រការ ១ នៃសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ នូវខ្លឹមសារសហគ្រាសធុនតូច មធ្យម ដោយអានថា : ឃ- ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារអភិបាលកិច្ច និងសហគ្រាសធុនតូច - មធ្យម ។

www.pheakdeylaw.com

**ប្រការ ៤** : ក្រុមការងារផ្នែកសេវា រាប់បញ្ចូលទាំងសេវាធនាគារ និងហិរញ្ញវត្ថុ ត្រង់ចំណុច " ង " ដែលមានចែងក្នុងសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ ត្រូវចាត់ទុកជានិរាករណ៍ ។

ក្រៅពីនេះ ខ្លឹមសារដែលមានចែងក្នុងសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ នៅរក្សាទុកជាធរមានដដែល ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល អាជ្ញាធរអប្សរា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

www.pheakdeylaw.com